

USDA

USAID
ជំនួយពីប្រជាជនអាមេរិក

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

ខែមករា ឆ្នាំ២០២៤

WFP
World Food Programme

SAVING LIVES
CHANGING LIVES

## ប្រទេសកម្ពុជា

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ


**វិភាគ និងធ្វើផែនទីភាពងាយរងគ្រោះ (VAM)**
ផ្នែកស្រាវជ្រាវ វាយតម្លៃ និងតាមដាននៃកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org ,
ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**គិតត្រឹមដើមឆ្នាំ២០២៤ អតិផរណាស្បៀងអាហារសកល នៅតែមានកម្រិតខ្ពស់។** និន្នាការកើនឡើងជាបន្តបន្ទាប់នេះគឺបង្កឡើងដោយជម្លោះភូមិសាស្ត្រនយោបាយកំពុងបន្ត ឥទ្ធិពលនៃបាតុភូតអែលនីញូលើពាណិជ្ជកម្ម និងកសិកម្មសកល និងការបិទការនាំចេញស្បៀងអាហាររបស់ប្រទេសជាអ្នកផលិតសំខាន់ៗ។ កត្តាទាំងនេះរួមចំណែកធ្វើឱ្យទីផ្សារស្បៀងអាហារពិភពលោក ប្រឈមនឹងបញ្ហាតម្លៃ ក៏ដូចជាលទ្ធភាពទទួលបានស្បៀងអាហារសំខាន់ៗ។

**ក្នុងខែមករា ឆ្នាំ២០២៤ សន្ទស្សន៍តម្លៃម្ហូបអាហារពិភពលោករបស់ FAO បានថយចុះ ១០,៤% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY) និង ថយចុះ ១,០% ធៀបនឹងខែមុន (MoM)។** ភាពប្រសើរឡើងនេះដោយសារតែតម្លៃធញ្ញជាតិ និងសាច់បានថយចុះច្រើនជាងការកើនឡើងតម្លៃស្ករ ខណ:តម្លៃប្រេងឆា និងផលិតផលទឹកដោះគោមានការប្រែប្រួលតិចតួចប៉ុណ្ណោះ។ សន្ទស្សន៍តម្លៃអង្ករសរុបរបស់ FAO នៅតែបន្តកើនឡើងបន្តិច ១,២% MoM ប៉ុន្តែកើនឡើងខ្លាំង ១៣,០% YoY។

**តម្លៃអង្ករសកលត្រូវបានព្យាករថានឹងនឹងកើនឡើង ៦% ក្នុងឆ្នាំ២០២៤** បន្ទាប់ពីបានកើនឡើង ២៨% ក្នុងឆ្នាំ២០២៣។ ការកើនឡើងតម្លៃអង្ករ ដែលបង្កឡើងដោយតម្រូវការកើនឡើង និងការផ្គត់ផ្គង់ថយចុះ កំពុងបង្កើនក្តីបារម្ភពីអសន្តិសុខស្បៀងពិភពលោក ដោយសារអង្ករជាអាហារចម្បងសម្រាប់មនុស្សជាង ៣ ពាន់លាននាក់។

**ម្យ៉ាងទៀត ការធ្លាក់ចុះនៃកម្ពស់ទឹកទន្លេ ដែលបង្កឡើងដោយបាតុភូតអែលនីញូ** កំពុងរំខានដល់ផ្លូវពាណិជ្ជកម្មសំខាន់ៗ ដែលបង្កឱ្យមានបញ្ហាជាខ្លាំងដល់ពាណិជ្ជកម្មពិភពលោក។ ការរអាក់រអួលទាំងនេះ កំពុងធ្វើឱ្យមានការយឺតយ៉ាវលើការដឹកជញ្ជូន ការកើនឡើងតម្លៃដឹកជញ្ជូន ក៏ដូចជាប៉ះពាល់ដល់តម្លៃនាំចូល និងតម្លៃលក់រាយស្បៀងអាហារផងដែរ។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀង នៅតាមផ្សារនានាក្នុងប្រទេសកម្ពុជា** កម្មវិធីស្បៀងអាហារពិភពលោក (WFP) តាមដានតម្លៃស្បៀងអាហារសំខាន់ៗ និងដំណើរការរបស់ផ្សារចំនួន៥៨។ ក្នុងខែមករា ឆ្នាំ ២០២៤ ប្រធានផ្សារ និងអាជីវករ ចំនួនប្រហែល ១.០០០ នាក់ ត្រូវបានសម្ភាសន៍នៅសប្តាហ៍ទីបីនៃខែនីមួយៗ ដើម្បីវាយតម្លៃពីការផ្គត់ផ្គង់ និងតម្រូវការ។ តម្លៃប្រេងសាំង ប្រេងម៉ាស៊ូត និងប្រាក់ឈ្នួលពលកម្មក៏ត្រូវបានតាមដានផងដែរ។

# មាតិកា


១. កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ ២
២. របកគំហើញសំខាន់ៗ ៣
៣. លទ្ធផល
ការដំណើរការរបស់ផ្សារ ៤
ការទៅផ្សារ៖ និន្នាការអតិថិជន ៥
ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦
ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រីកួន ៧
ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូកបីជាន់ និងប្រេងឆា ៨
ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន ៩
ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ ១០
ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១១
ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១២
៤. បរិបទ
ពាណិជ្ជកម្ម ១៣
ការឆ្លើយតបផ្នែកនយោបាយ ១៤
៥. វិធីសាស្ត្រ និងទីតាំងផ្សារ ១៥
៦. ឧបសម្ព័ន្ធទី១
បម្រែបម្រួលថ្លៃលក់រាយ ១៦
៧. ឧបសម្ព័ន្ធទី២
បម្រែបម្រួលថ្លៃលក់ដុំ ១៧
៨. ឧបសម្ព័ន្ធទី៣
តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៨

# ទិដ្ឋភាពទូទៅ

**កំណើនសេដ្ឋកិច្ច**

| ២០២២ | ២០២៣ | ២០២៤ |
|---|---|---|
| ៥.២% | ៥.៤% (ប៉ាន់ស្មាន) | ៦.០% (ព្យាករណ៍) |

*ក្នុងខែមករា ឆ្នាំ២០២៤ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រួម (CPI) និងសន្ទស្សន៍តម្លៃស្បៀងអាហារ (FPI) នៅរាជធានីភ្នំពេញ បានថយចុះ បើធៀបនឹងខែមុន ក៏ដូចជាឆ្នាំមុន។ ប៉ុន្តែ សន្ទស្សន៍ទាំង២ នៅតែខ្ពស់ជាងឆ្នាំ២០២២។ គួរកត់សម្គាល់ថា គ្រួសារកម្ពុជាចំណាយលើស្បៀងអាហារច្រើនគួរសម គឺ៥២% នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ។ គ្រួសារក្នុងក្រុមចំណាយទាបបំផុតបានចំណាយ រហូតដល់៥៨% (CSES ២០២១)។*

**អតិផរណា**




*តម្លៃប្រេងឥន្ធនៈនៅកម្ពុជា ក្នុងខែមករា ឆ្នាំ២០២៤ បានបន្តថយចុះបង្គួរ។ ការថយចុះនេះទំនងជាដោយសារកំណើននៃការផ្គត់ផ្គង់ពីប្រទេសមិនមែន OPEC+ ចំពេលដំណាលគ្នាជាមួយនឹងការថយចុះនៃតម្រូវការសកល។ ប៉ុន្តែ តម្លៃប្រេងម៉ាស៊ូតនៅតែខ្ពស់ជាងខែដូចគ្នាឆ្នាំ២០២២ ជាពេលដែលតម្លៃខ្ពស់រួចទៅហើយ។*

**ប្រេងឥន្ធនៈ**




# របកគំហើញសំខាន់ៗ

**ក្នុងខែមករា ឆ្នាំ២០២៤ កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) បានថយចុះបង្គួរ ៣,២% ធៀបនឹងខែមុន (MoM) ធ្លាក់ដល់តម្លៃ ២៦,៥ ដុល្លារ ក្នុងម្នាក់ក្នុងមួយខែ។** ការថយចុះនេះដោយសារតែតម្លៃស្បៀងអាហារភាគច្រើនបានថយចុះ លើកលែងអង្ករ និងជំឡូងជ្វា។ តម្លៃអង្ករចម្រុះបានបន្តនិន្នាការកើនឡើង គឺ ១,២% MoM និង ៣២,៣% YoY។

**អំណាចទិញកញ្ចប់ស្បៀងអាហារមានភាពល្អប្រសើរបង្គួរ ក្នុងខែមករា ឆ្នាំ ២០២៤** ដោយសារការបន្តថយចុះនៃតម្លៃកញ្ចប់ស្បៀងអាហារ និងភាពប្រសើរឡើងនៃប្រាក់ឈ្នួលពលកម្មគ្មានជំនាញ។ ទោះជាយ៉ាងណា ចំនួនអតិថិជនមកផ្សារមានការថយចុះ អាចដោយសារមានកំណើនតូបលក់ស្បៀងអាហារតូចៗច្រើនសម្រាប់អតិថិជន។ ផ្សារមានដំណើរការល្អនៅទូទាំងប្រទេស។

**ក្នុងខែមករា ឆ្នាំ២០២៤ ការដាំដុះស្រូវប្រាំងសម្រេចបានលើសផែនការ ២៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។** ការកើនឡើង ដែលមិនធ្លាប់មានទីមុនមកនេះភាគច្រើនមាននៅខេត្តពោធិសាត់ និងខេត្តបាត់ដំបង។ វាអាចដោយសារតែមានការកើនឡើងខ្ពស់នៃតម្លៃអង្ករ ដែលជាកត្តាលើកទឹកចិត្តដល់កសិករ រួមនឹងការថយចុះនៃតម្លៃធាតុចូល ដូចជាប្រេងឥន្ធនៈ និងជីកសិកម្ម។

**ប៉ុន្តែ កំណើនការដាំដុះដំណាំស្រូវក៏បានធ្វើឱ្យជួបនឹងបញ្ហាកង្វះទឹក** ដែលបានកើតឡើងរួចមកហើយនៅក្នុងឃុំមួយចំនួន។ លើសពីនេះទៀត តំបន់ដាំដុះជាច្រើន ពិសេសនៅភាគនិរតីនៃប្រទេស ទទួលបានទឹកភ្លៀងទាប និងមានសីតុណ្ហភាពខ្ពស់ បង្កឡើងដោយស្ថានភាពអែលនីញូនាពេលបច្ចុប្បន្ន។

# ការដំណើរការរបស់ផ្សារ

ក្នុងខែមករា ឆ្នាំ២០២៤ សន្ទស្សន៍ដំណើរការរបស់ផ្សារ* (MFI) បានកើនឡើងបង្គួរ ធៀបនឹងខែមុន។ នេះដោយសារតែតម្លៃទំនិញសំខាន់ៗមានស្ថេរភាព ដែលលុបលើការថយចុះបន្តិចនៃភាពមានស្បៀងក្នុងបរិមាណគ្រប់គ្រាន់។ ប្រធានផ្សារ និងអ្នកលក់តាមបណ្ដាផ្សារត្រូវបានសម្ភាសន៍ស្ដីពីស្ថានភាពនៃការផ្គត់ផ្គង់ស្បៀងអាហារ។ នៅក្នុងខែមករា ឆ្នាំ២០២៤ យ៉ាងហោចណាស់មានប្រធានផ្សារ និងអ្នកលក់ដែលបានសម្ភាសន៍ ចំនួន ៩នាក់ បានរាយការណ៍ថាមានការកើនឡើងតម្លៃផ្គត់ផ្គង់ស្បៀងអាហារសំខាន់ពិសេសគឺអង្ករ។




** សន្ទស្សន៍ដំណើរការផ្សារ (MFI) វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ សមាសធាតុនីមួយៗនៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់ បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សារជារួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ <u>លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ</u>។ ចាប់ពីពាក់កណ្ដាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។ ចាប់ពីខែមេសា ឆ្នាំ២០២៣មក ការគណនា MFI និងសមាសធាតុសំខាន់ៗត្រូវបានកែសម្រួលដើម្បីបង្ហាញព័ត៌មានកាន់តែសុក្រិត។*

# ការនៅផ្សារ៖ ទិន្នាការអតិថិជន

នៅក្នុងខែមករា ឆ្នាំ២០២៤ មានការថយចុះបង្គួរនូវចំនួនអតិថិជនទៅផ្សារបើធៀបនឹងខែមុន។ ការថយចុះនេះអាចបណ្តាលមកអស្ថេរភាពនៃប្រាក់ចំណូលនៅក្នុងគ្រួសារ ដែលកំហិតការចំណាយរបស់គ្រួសារ។លើសពីនេះ  ការកើនឡើងនៃតូបលក់ស្បៀងអាហារតូចៗនៅតាមភូមិបានកាត់បន្ថយតម្រូវការសម្រាប់ប្រជាជនក្នុងការធ្វើដំណើរទៅកាន់ផ្សារធំដើម្បីទិញស្បៀងអាហារ។




**បម្រែបម្រួលនៃចំនួនអតិថិជន*មកផ្សារ**

** ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារចំនួន ៥៦ កន្លែង ដែលបានតាមដានតម្លៃនៅទូទាំងប្រទេស ក៏ត្រូវបានសម្ភាសន៍ស្តីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សារនៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣ នៃខែនីមួយៗ ដោយប្រៀបធៀបទៅនឹងរយៈពេលពីរសប្តាហ៍មុន។ តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងសេរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

បើទោះជាតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន[1] (BFB) បានថយចុះ ៣,២% ធៀបនឹងខែមុន (MoM) តាំងពីខែធ្នូ ឆ្នាំ២០២៣ ក៏វានៅតែមានតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន (YoY) ២,៩%។ ក្នុងខែមករា ឆ្នាំ២០២៤ តម្លៃកញ្ចប់ស្បៀងអាហារជាមធ្យមគឺ ១០៨.៦០០ រៀល/ម្នាក់/ខែ មានតម្លៃប្រហែល ២៦,៥ ដុល្លារ។ តម្លៃ BFB នៅផ្សារតំបន់ទីប្រជុំជន[2] (២៦,៧ ដុល្លារ -៣,៩% MoM +០,៧% YoY) នៅតែមានតម្លៃខ្ពស់ជាតម្លៃកញ្ចប់នៅផ្សារជនបទ (២៦,២ ដុល្លារ -១,៤% MoM +៤,១% YoY)។




[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាន់នៅកម្ពុជា។

[2] ផ្សារនៅទីប្រជុំជនសំដៅដល់ផ្សារដែលស្ថិតនៅទីរួមខេត្ត ហើយផ្សារដទៃទៀតចាត់ទុកថាជាផ្សារនៅជនបទ។

## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែមករា ឆ្នាំ២០២៤ តម្លៃលក់រាយអង្ករចម្រុះបានកើនឡើងបន្តិច គឺ ១,២% ធៀបនឹងខែមុន (MoM) ប៉ុន្តែបានកើនឡើងគួរឱ្យកត់សម្គាល់ គឺ ៣២,៧% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY)។ តម្លៃលក់រាយស៊ុតទា និងត្រកួនបានថយចុះគួរឱ្យកត់សម្គាល់ ទាំង MoM និង YoY ដោយតម្លៃស៊ុតទាបានថយចុះ ៧,៣% MoM និង ៦,៤% YoY ហើយតម្លៃត្រកួនបានថយចុះ ៩,៣% MoM និង ៦,៦% YoY។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




*សម្គាល់៖*

*- ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។*

*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូកបីជាន់ និងប្រេងឆា

ក្នុងខែមករា ឆ្នាំ២០២៤ តម្លៃលក់រាយប្រេងឆា សាច់ជ្រូកបីជាន់ និងត្រីផ្ទក់ បានបន្តថយចុះ ទាំងធៀបនឹងខែមុន (MoM) ក៏ដូចជាធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY)។ តម្លៃប្រេងឆាបានថយចុះ ២,៨% MoM និង ១៥,២% YoY តម្លៃសាច់ជ្រូកបីជាន់បានថយចុះ ៣,៩% MoM និង ១២,៩% YoY និងតម្លៃត្រីផ្ទក់បានថយចុះ ២,៤% MoM និង ៣,៩% YoY។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




*សម្គាល់៖ តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

ក្នុងខែមករា ឆ្នាំ២០២៤ តម្លៃមធ្យមលក់រាយស្បៀងអាហារដែលបានតាមដានភាគច្រើន (ក្រាហ្វិកខាងក្រោមឆ្វេង) មានទិសដៅប្រែប្រួលដូចគ្នា ទាំងនៅផ្សារជនបទ និងផ្សារទីប្រជុំជន ដោយតម្លៃភាគច្រើនបានថយចុះ។ ប៉ុន្តែ តម្លៃអង្ករចម្រុះ និងជំឡូងផ្កាពណ៌លឿង បានកើនឡើង។

តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានរបស់ WFP មានការប្រែប្រួលតាមបណ្តាខេត្ត (ផែនទីខាងក្រោមស្តាំ) ដោយនៅផ្សារបារាយណ៍ ក្នុងខេត្តកំពង់ធំ (៣០,០ ដុល្លារ) គឺខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ១៣% ខណៈនៅផ្សារស្ទោង ក្នុងខេត្តកំពង់ធំ (២៣,២ ដុល្លារ) គឺទាបជាងតម្លៃមធ្យមថ្នាក់ជាតិ ១២%។ តម្លៃកញ្ចប់ស្បៀងអាហារដែលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ពិសេសតម្លៃខ្ពស់ជាង ១០% ភាគច្រើនមាននៅផ្សារនៅជនបទ។

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ
ខែធ្នូ ឆ្នាំ២០២៣ និង ខែមករា ឆ្នាំ២០២៤




*សម្គាល់៖*
*- ទិន្នន័យតម្លៃពីផ្សារចំនួន៥៨។ មើលវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*
*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

## តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹង
តម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែមករា ឆ្នាំ២០២៤)



| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | ១០០% | ០% |
| ៥% ទៅ ១០% ខ្ពស់ជាង | ០% | ១០០% |
| < ៥% ខ្ពស់ជាង | ៤៧% | ៥៣% |
| < ៥% ទាបជាង | ៤៧% | ៥៣% |
| ៥% ទៅ ១០% ទាបជាង | ៤៤% | ៥៦% |
| ≥ ១០% ទាបជាង | ១០០% | ០% |

# ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ

ការិយាល័យទីផ្សារកសិកម្ម (AMO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ប្រមូលទិន្នន័យស្តីពីប្រាក់ឈ្នួលពលកម្មសម្រាប់កម្មករក្នុងវិស័យកសិកម្ម និងសំណង់ជារៀងរាល់ខែនៅទូទាំងប្រទេស។ ក្នុងខែមករា ឆ្នាំ២០២៤ ប្រាក់ឈ្នួលពលកម្មមធ្យមថ្នាក់ជាតិ[1] សម្រាប់កម្មករគ្មានជំនាញមានស្ថេរភាពធៀបនឹងខែមុន ដែលមានតម្លៃ ៣៦.២០០ រៀលក្នុងមួយថ្ងៃ ប្រហែល ៨,៨ ដុល្លារ។ ប៉ុន្តែ វាបានកើនឡើងគួរឱ្យកត់សម្គាល់ គឺ ១០,៩% ធៀបនឹងខែដូចគ្នាកាលពីខែមុន។

កម្លាំងទិញស្បៀងអាហារ (ToT) ត្រូវបានប្រើសម្រាប់វាយតម្លៃពីកម្លាំងទិញស្បៀងអាហាររបស់គ្រួសារ ហើយត្រូវបានវាស់វែងដោយប្រើផលធៀបរវាងអត្រាប្រាក់ឈ្នួលកម្មករគ្មានជំនាញប្រចាំថ្ងៃ និងតម្លៃមធ្យមកញ្ចប់ស្បៀងអាហារមូលដ្ឋានប្រចាំថ្ងៃ[2]។ ក្នុងខែមករា ឆ្នាំ២០២៤ ToT បានបង្ហាញកំណើន ២,៩% ធៀបនឹងខែមុន និងកើនឡើងគួរឱ្យកត់សម្គាល់ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ និន្នាការនេះបង្ហាញពីភាពប្រសើរឡើងនៃលទ្ធភាពទិញកញ្ចប់ស្បៀងអាហារមូលដ្ឋានរបស់កម្មករគ្មានជំនាញ។ ការកើនឡើងកម្លាំងទិញគឺដោយសារការបន្ថយចុះនៃតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលទូទាត់នឹងការថយចុះបន្តិចនៃប្រាក់ឈ្នួលពលកម្ម។

ប្រាក់ឈ្នួលពលកម្ម
(ខែមករា ឆ្នាំ២០២៤)




កម្លាំងទិញស្បៀងអាហារ
(ខែមករា ឆ្នាំ២០២៤)




*[1] នេះជាប្រាក់ឈ្នួលពលកម្ម ដែលមិនទាន់បានកែសម្រួលជាមួយអតិផរណា*

*[2] តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) ត្រូវបានគណនាជារៀងរាល់ខែដើម្បីបង្ហាញពីតម្លៃក្នុងមួយខែ។ ប៉ុន្តែ ដើម្បីគណនាកម្លាំងទិញស្បៀងអាហារ (ToT) តម្លៃក្នុងមួយខែនេះត្រូវបានបំលែងទៅជាតម្លៃក្នុងមួយថ្ងៃ ដើម្បីផ្តល់តម្លៃប៉ាន់ស្មានក្នុងមួយថ្ងៃ។*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

ក្នុងខែមករា ឆ្នាំ២០២៤ កម្ពុជាទទួលបានទឹកភ្លៀងជាមធ្យមសរុប* ទាបជាងមធ្យមភាគច្រើនឆ្នាំ (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ បណ្ដាខេត្តភាគច្រើននៅភាគខាងត្បូង និងភាគខាងលិចទទួលបានទឹកភ្លៀងទាបជាងមធ្យមភាគច្រើនឆ្នាំ ខណៈខេត្តនៅភាគឦសានទទួលបានទឹកភ្លៀងធម្មតា (ផែនទីខាងក្រោមខាងស្ដាំ)។

ការព្យាករ El Niño, La Niña និង Southern Oscillation (ENSO) បានបង្ហាញថា បាតុភូតអែលនីញ៉ូត្រូវបានព្យាករថានឹងបន្តរហូតដល់ខែឧសភា ឆ្នាំ២០២៤ ដែលធ្វើឱ្យមានស្ថានភាពកាន់តែក្ដៅ និងកាត់តែស្ងួត។ ផ្អែកតាមការព្យាករតាមរដូវកាលរបស់ International Research Institute (IRI) of Columbia University and European Centre for Medium-Range Weather Forecasts (ECMWF) ចន្លោះខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៤ ខេត្តភាគច្រើននៃប្រទេសកម្ពុជាទំនងទទួលបានទឹកភ្លៀងចន្លោះពីធម្មតាទៅទាបជាងធម្មតា និងមានសីតុណ្ហភាពខ្ពស់ជាងធម្មតា។ នេះទំនងជាបន្ថែមសម្ពាធលើការប្រើប្រាស់ទឹកសម្រាប់ផឹក សម្រាប់វិស័យកសិកម្ម និងសម្រាប់ឧស្សាហកម្ម ដែលកំពុងតែមានតម្រូវការខ្ពស់រួចទៅហើយក្នុងអំឡុងពេលនេះ។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (ខែមករា ឆ្នាំ២០២៤) និងប្រតិទិនដាំដុះតាមរដូវកាល




| | មករា–កុម្ភៈ | មីនា–មេសា | ឧសភា–មិថុនា | កក្កដា–តុលា | វិច្ឆិកា–ធ្នូ |
|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | ប្រមូលផល | | | រៀបចំដី និង សាបព្រោះ |
| ស្រូវរដូវវស្សា | ប្រមូលផល | | រៀបចំដី និង សាបព្រោះ | ស្ទូង / ដាំដុះ | ប្រមូលផល |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែមករា ឆ្នាំ២០២៤




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

** កម្ពស់ទឹកភ្លៀងជាមធ្យមសរុបសម្រាប់ខែមួយគឺជាផលបូកនៃកម្ពស់ទឹកភ្លៀងក្នុងរយៈពេល ៣ដេកាត (រៀងរាល់១០ថ្ងៃ) ក្នុងខែនោះ។*

# **ការតាមដានរដូវកាល៖** ស្ថានភាពរុក្ខជាតិ និងដំណាំ

នៅក្នុងខែមករា ឆ្នាំ២០២៤ បើទោះជាទឹកភ្លៀងមានកម្រិតទាប រុក្ខជាតិដែលស្ថិតនៅតំបន់ដាំដុះដំណាំភាគច្រើននៃប្រទេសកម្ពុជា មានស្ថានភាពចន្លោះពីធម្មតាទៅប្រសើរជាងធម្មតា (ផែនទីខាងស្តាំ) នេះដោយសារតែមានប្រព័ន្ធធារាសាស្ត្រ។

គិតត្រឹមខែមករា ឆ្នាំ២០២៤ ផ្ទៃដីដាំដុះស្រូវប្រាំង សម្រេចបានចំនួន ៨១៧.០០០ ហិកតា លើសឆ្នាំមុនក្នុងរយៈពេលដូចគ្នាចំនួន ២៣%។ ស្របគ្នានេះដែរ ផ្ទៃដីប្រមូលផលស្រូវប្រាំងសម្រេចបាន ២៦០.០០០ ហិកតា ដោយផ្តល់ទិន្នផលចំនួន ៤,៦ តោនក្នុងមួយហិកតា។

**ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI) ក្នុងខែមករា ឆ្នាំ២០២៤**




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*

# ពាណិជ្ជកម្ម

**ក្នុងខែមករា ឆ្នាំ២០២៤ ការនាំចេញផ្លូវការសរុប (មិនរាប់បញ្ចូលមាសមិនមែនរូបិយវត្ថុ) របស់កម្ពុជា បន្តនិន្នាការកើនឡើង ជាមួយនឹងការកើនឡើងគួរឱ្យកត់សម្គាល់ គឺ ២៧% ធៀបនឹងខែមុន** មានតម្លៃ ១.៩៦៧ លានដុល្លារ។ គោលដៅនាំចេញសំខាន់ រួមមាន សហរដ្ឋអាមេរិក វៀតណាម ចិន ជប៉ុន និងថៃ។ ការនាំចេញទំនិញជាស្បៀងអាហារចំនួន ២១០ លានដុល្លារ (ក្រាហ្វិកខាងស្តាំ) ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ១៧៧ លានដុល្លារ (+៧៨% YoY) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុង ដែលអាចបរិភោគបាន បន្លែដែលអាចបរិភោគបាន ឫស/មើម និងខ្លាញ់សត្វ ប្រេងរុក្ខជាតិ) ចំនួន ៣៣ លានដុល្លារ (+៦០ YoY)។ ក្នុងខែដំបូងឆ្នាំ២០២៤ ការនាំចេញអង្ករមានចំនួនសរុប ៩៦.២២១ តោន (មានតម្លៃស្មើ ៣២,៦ លានដុល្លារ) (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤)។ បរិមាណនាំចេញអង្ករនេះមានកំណើន ២៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ បន្ថែមលើនេះ ផ្អែកតាមប្រភពដដែលបង្ហាញថា ការនាំចេញស្រូវមានចំនួន ៦០០.០០០ តោន មានតម្លៃស្មើនឹង ១៨៤ លានដុល្លារ ត្រូវបាននាំចេញក្នុងរយៈពេលដូចគ្នា។

**ក្នុងខែមករា ឆ្នាំ២០២៤ ការនាំចូលជាផ្លូវការសរុប (មិនរាប់បញ្ចូលមាសមិនមែនរូបិយវត្ថុ) របស់កម្ពុជា ដោយកើនឡើងគួរឱ្យកត់សម្គាល់ គឺ ៣៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ** មានតម្លៃ ២.០៩០ លានដុល្លារ។ ការនាំចូលមានប្រភពមកពីប្រទេសចិន វៀតណាម ថៃ សឹង្ហបុរី និងម៉ាឡេស៊ី។ ក្នុងចំនោមការនាំចូលសរុប មានទំនិញជាស្បៀងអាហារចំនួន ១០៦ លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៧ លានដុល្លារ (+៦០% YoY) និងអាហារដទៃទៀត ចំនួន ៩៩ លានដុល្លារ (+៧% YoY)។ ក្នុងរយៈពេលដូចគ្នា ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្មចំនួន ២៦ លានដុល្លារ (+៤៣% YoY) ភាគច្រើនមកពីប្រទេសវៀតណាម ថៃ និងចិន និងប្រេងឥន្ធនៈ មានតម្លៃ ៣០៨ លានដុល្លារ (+៨% YoY)។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជា លានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ ត្រឹមខែមករា ឆ្នាំ២០២៤




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ចូលថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២៤*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ចាប់ពីខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះនៅទូទាំងប្រទេស ដែលប៉ះពាល់ដោយការរាតត្បាតកូវីដ-១៩។ គ្រួសារក្រីក្រលើសពី **៧០៩.០០០ គ្រួសារ** (ប្រមាណ ២,៧៧ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន **១.៣០៦ លានដុល្លារ** គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤។ កម្មវិធីនេះនឹងត្រូវបិទបញ្ចប់នៅក្នុងខែមីនា ឆ្នាំ២០២៤។ កម្មវិធីនេះនឹងបន្តជាមួយនឹង **"ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមថ្មី"ក្នុងកញ្ចប់គ្រួសារ** ដែលនឹងចាប់ផ្តើមចាប់ពីខែមេសា ឆ្នាំ២០២៤ តទៅ ជាមួយនឹងថវិកាបម្រុងសរុបចំនួន <u>**១៦៥ លានដុល្លារ**</u>។

រដ្ឋាភិបាល តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងដាក់ឱ្យប្រើប្រាស់**ប្រព័ន្ធសន្តិសុខសង្គមសម្រាប់ការថែទាំសុខភាពកុមារ។** គំនិតផ្តួចផ្តើមនេះផ្តល់អាទិភាពដល់សុខុមាលភាពរបស់កុមារ និងមានគោលបំណងលើកកម្ពស់សុខភាពរបស់ពួកគេ សម្រាប់ការអភិវឌ្ឍធនធានមនុស្សនាពេលអនាគត (<u>ដកស្រង់ដោយកាសែតខ្មែរថាម ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤</u>) ។

រដ្ឋាភិបាលគ្រោងថវិកាប្រមាណ **៤៥០ លានដុល្លារ ដើម្បីពង្រឹងសេវាថែទាំសុខភាពសម្រាប់ប្រជាជនប្រមាណ ៩ លាននាក់ នៅទូទាំងប្រទេស។** លើសពីនេះ វាមានគោលបំណងជួយគាំទ្រដល់សេវាសាធារណៈផ្សេងទៀត ជាពិសេសសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ ដោយស្របតាមគោលនយោបាយជាតិគាំពារសង្គម (<u>ដកស្រង់ដោយកាសែតខ្មែរថាម ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤</u>)។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

រដ្ឋាភិបាល គ្រោងនឹង**ដាក់បម្រាមបណ្តោះអាសន្នលើការនាំចូលសាច់ក្រក និងសាច់ក្លាសេ** លើកលែងតែទំនិញនាំចូលមានគុណភាពគ្រប់គ្រាន់ សម្រាប់រយៈពេល៦ខែ។ ទោះយ៉ាងណាក៏ដោយ ដោយសារការហាមប្រាមមិនអាចមានជាអចិន្ត្រៃយ៍ កម្ពុជាគួរតែស្វែងរកឱកាសវិនិយោគក្នុងស្រុក ដើម្បីបង្កើនការប្រកួតប្រជែង (<u>ដកស្រង់ដោយកាសែតខ្មែរថាម ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤</u>)។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) ត្រៀមថវិកាចំនួន **១០០ លានដុល្លារ សម្រាប់កម្មវិធីរបស់រដ្ឋាភិបាល ដើម្បីរក្សាស្ថិរភាពតម្លៃកសិផល។** វាគាំទ្រដល់រោងម៉ាស៊ីនកិនស្រូវ/អ្នកនាំចេញ ជាមួយនឹងការផ្តល់ហិរញ្ញប្បទានដើមទុនធ្វើការ ជំនួយដល់លទ្ធកម្មអង្ករ ធានាស្ថិរភាពតម្លៃ និងជំរុញសន្តិសុខស្បៀង និងការនាំចេញរបស់កម្ពុជា (<u>ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤</u>)។

សេដ្ឋកិច្ចកម្ពុជាកំពុងតែផ្លាស់ប្តូរពីការងារប្រើកម្លាំងពលកម្មទៅជាការងារប្រើជំនាញ ដែលជំរុញដោយបច្ចេកវិទ្យា។ ផែនទីបង្ហាញផ្លូវឆ្នាំ២០២៣-២០៣៥ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានគោលបំណងផ្តល់ឱ្យប្រជាពលរដ្ឋគ្រប់រូបនូវជំនាញវិជ្ជាជីវៈ យ៉ាងតិចមួយមុខ តាមរយៈឱកាសសិក្សារួម ដោយកំណត់ផ្លូវឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើជំនាញ ដើម្បីផ្សារភ្ជាប់គម្លាតនៃការអប់រំ (<u>ដកស្រង់ដោយកាសែតខ្មែរថាម ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៤</u>)។




*ប្រភព៖ រូបភាពត្រូវបានបង្កើតឡើងដោយ ChatGPT*




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្តើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៩ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្តប់ដល់ ៥៦ ផ្សារ។

ក្នុងខែមករា ឆ្នាំ២០២៤ WFP បានបន្ថែមផ្សារចំនួន ២ ទៀត (ឈ្មោះថា ផ្សារបត់រំដួល និងផ្សារភ្នំក្រវាញ) ដែលស្ថិតក្រោមការសាកល្បងលទ្ធកម្មថ្មីរបស់កម្មវិធី HGSFP ដែលមានទីតាំងនៅខេត្តពោធិ៍សាត់ ហើយបានប្រមូលទិន្នន័យតម្លៃទំនិញចំនួន ៧៨ មុខ ក្នុងនោះមានទំនិញជាស្បៀងអាហារបន្ថែមចំនួន ២៧ មុខ (សូមមើលឧបសម្ព័ន្ធទី ១ & ២)។ តម្លៃទំនិញជាស្បៀងអាហារដែលបានបន្ថែមចំនួន ២៧ មុខនេះក៏នឹងប្រមូលជាប្រចាំនៅក្នុងខេត្តដែលមានកម្មវិធី HGSFP ផ្សេងទៀតផងដែរ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| អង្ករចម្រុះ | Kg | 2,833 | → 3.8% | → 4.2% | ↑ 35.7% |
| អង្ករបាក់៣០-៣៥% | Kg | 2,800 | • | • | • |
| ត្រីផ្ទក់(រស់) | Kg | 10,347 | → -2.4% | ↓ -13.7% | → -3.9% |
| ត្រីប្រា(រស់) | Kg | 6,800 | ↓ -5.9% | ↓ -8.8% | → -0.5% |
| ត្រីអណ្តែង(រស់) | Kg | 7,867 | → 4.2% | → -3.6% | → 2.9% |
| ត្រីងៀត(ផ្ទក់) | Kg | 26,702 | → -1.3% | → -2.5% | → 1.6% |
| ប្រហុក | Kg | 9,264 | → -2.5% | → 3.4% | → 3.2% |
| ត្រីពោធិ៍ | Kg | 10,333 | • | • | • |
| ត្រីខ្យា | Kg | | • | • | • |
| ត្រីសណ្តាយ | Kg | | • | • | • |
| សាច់ជ្រូកពាជាន់ | Kg | 13,954 | ↓ -6.1% | ↓ -9.8% | ↓ -14.9% |
| ឆ្អឹងជំនីជ្រូក | Kg | 12,667 | • | • | • |
| ឆ្អឹងជ្រូកស៊ុប | Kg | 10,000 | • | • | • |
| ជើងជ្រូក | Kg | 10,000 | • | • | • |
| សាច់គោឃារ | Kg | 15,524 | ↓ -5.3% | ↓ -8.5% | ↓ -20.5% |
| សាច់មាន់ (បីសាសន៍) | Kg | 14,295 | ↑ 7.2% | → -1.9% | → 0.7% |
| សាច់មាន់ (ស៊ីភី) | Kg | 10,000 | • | • | • |
| ស៊ុតទា | 10 eggs | 5,025 | ↓ -7.3% | ↓ -13.0% | ↓ -6.4% |
| ស៊ុតទាប្រៃ | 10 eggs | 6,972 | → -1.0% | → -3.8% | → 0.4% |
| ប្រេងឆា | 5 litres | 24,717 | → -4.9% | ↓ -7.3% | ↓ -17.1% |
| អំបិលម៉ត់អ៊ីយូត | Kg | 1,273 | → 2.5% | → 0.5% | → -4.6% |
| ទឹកត្រី (រូបបង្កងប៉ាក) | 730 ml | 3,425 | → -1.1% | → -0.2% | → 1.3% |
| សណ្តែកដី* | Kg | 9,774 | → -3.9% | → -1.6% | → -1.8% |
| សណ្តែកសៀង | Kg | 5,568 | ↑ 7.4% | → 0.3% | → 3.5% |
| សណ្តែកខៀវ | Kg | 5,933 | → -0.8% | → -0.7% | → 0.3% |
| ត្រកួន | Kg | 2,808 | ↓ -14.6% | ↓ -14.0% | ↓ -12.0% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ការ៉ុត* | Kg | 3,063 | → -1.8% | → -3.0% | ↓ -12.4% |
| ស្លឹកបាស* | Kg | 4,655 | → -4.0% | ↓ -6.3% | ↓ -6.8% |
| ស្លឹកម្រុំ* | Kg | 5,850 | ↑ 14.5% | ↑ 12.4% | ↑ 15.2% |
| ស្ពៃក្រញាញ់* | Kg | 3,148 | ↓ -12.0% | ↓ -34.1% | ↓ -10.1% |
| ស្ពៃតឿ* | Kg | 3,248 | ↓ -7.8% | ↓ -26.9% | → -4.6% |
| ស្ពៃចង្កឹះ | Kg | 2,953 | ↓ -8.0% | ↓ -28.9% | → -0.2% |
| ស្ពៃខៀវ* | Kg | 3,079 | ↓ -13.4% | ↓ -22.8% | → -3.1% |
| ផ្កីដូង* | Kg | 3,504 | ↓ -17.1% | ↓ -16.7% | ↓ -18.1% |
| ស្លឹកងប់* | Kg | 5,544 | → 0.7% | → 2.4% | ↑ 5.2% |
| ត្រយលោ្ត* | Kg | 5,081 | → -2.6% | ↑ 11.3% | ↑ 5.9% |
| ផ្លែល្ពៅ* | Kg | 2,443 | → -3.2% | → 1.6% | ↓ -15.2% |
| ឃ្លោក* | Kg | 2,675 | ↓ -7.4% | → 2.3% | • |
| ត្រឡាច | Kg | 2,870 | ↑ 16.2% | ↑ 14.8% | ↑ 25.7% |
| ត្រប់វែង | Kg | 2,985 | → -3.3% | → -0.2% | ↓ -21.0% |
| ត្រប់ស្រួយ* | Kg | 3,309 | ↓ -5.9% | ↑ 6.3% | ↓ -10.8% |
| ប៉េងប៉ោះ* | Kg | 3,443 | ↓ -30.6% | ↓ -15.3% | ↓ -20.3% |
| ននោងមូល | Kg | 2,514 | ↓ -12.7% | ↓ -10.0% | ↓ -16.6% |
| ននោងជ្រុង* | Kg | 2,685 | ↓ -8.2% | ↓ -5.6% | ↓ -11.1% |
| ល្ហុងខ្ចី* | Kg | 1,281 | → 0.8% | → -4.2% | ↓ -24.7% |
| សណ្តែកកួរ | Kg | 4,638 | → 3.7% | ↑ 20.8% | ↑ 21.9% |
| ត្រយូងចេក* | Kg | 2,377 | → 4.9% | → -1.8% | ↑ 5.4% |
| ផ្កាខាត់ណា* | Kg | 4,841 | ↓ -31.4% | ↓ -39.1% | ↓ -14.3% |
| ដើមខាត់ណា* | Kg | 4,056 | ↓ -28.4% | ↓ -33.0% | ↓ -11.2% |
| ដំឡូងផ្កាពណ៌លឿង* | Kg | 2,230 | ↓ -13.3% | ↓ -13.0% | ↓ -29.3% |
| ខ្ទឹមសរ | Kg | 7,073 | → -1.1% | → -0.7% | ↑ 37.3% |
| អំពិលទុំ (មានគ្រាប់) | Kg | 3,756 | ↓ -5.2% | → -3.1% | ↓ -8.7% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| អំពិលទុំ (អត់គ្រាប់) | Kg | 8,000 | • | • | • |
| ព្រលឹត | Kg | 3,333 | • | • | • |
| ត្រួយស្ពៃ | Kg | 16,333 | • | • | • |
| ត្រួយននោង | Kg | 3,187 | • | • | • |
| ត្រួយ ឬ ផ្កាអង្គារ៍ដី | Kg | 7,667 | • | • | • |
| ផ្សិតអំបោះ | Kg | 8,000 | • | • | • |
| ស្ពៃក្តោប | Kg | 2,500 | • | • | • |
| ស្ពៃបូកគោ | Kg | 3,333 | • | • | • |
| សណ្តែកបណ្តុះ | Kg | 2,667 | • | • | • |
| ក្តឹបឱឡឹក | Kg | 2,208 | • | • | • |
| ពោតបារាំង | Kg | 5,333 | • | • | • |
| ស្ងៀតពោត | Kg | 2,333 | • | • | • |
| ផ្លែពោត | Kg | 3,333 | • | • | • |
| ផ្លែត្នោតខ្ចី(ចិតរួច) | Kgl | 5,000 | • | • | • |
| ត្រសក់ | Kg | 2,000 | • | • | • |
| ម្ទេសត្រាវ | Kg | 4,500 | • | • | • |
| ម្ទេសផែថាវ | Kg | 2,458 | • | • | • |
| ទំពាំង | Kg | 8,167 | • | • | • |
| ចេកណាំវ៉ាទុំ | Kg | 2,102 | → -2.8% | ↓ -7.2% | → -2.5% |
| ស្វាយកែវរមៀតទុំ | Kg | 2,500 | → 0.0% | ↑ 75.4% | ↓ -21.1% |
| ម្នាស់ទុំ | Kg | 2,912 | • | • | • |
| ទឹកដោះគោស្រស់ | 140 ml | 1,980 | → -3.5% | ↓ -6.9% | ↑ 20.2% |
| កូកាកូឡា | 330 ml | 1,997 | → -0.1% | → -0.1% | → 0.5% |
| សាំងធម្មតា | litre | 4,111 | → -2.4% | ↓ -8.6% | → -2.9% |
| ម៉ាស៊ូត | litre | 4,093 | → -1.9% | ↓ -10.8% | ↓ -9.6% |
| ជីអ៊ុយរ៉េ | Kg | 2,764 | → -4.5% | ↓ -6.6% | ↓ -21.0% |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%

→ ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%

↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%

• គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ ឆ្នាំមុន |
|---|---|---|---|---|---|
| អង្ករចម្រុះ | Kg | 2,833 | → 3.8% | → 4.2% | ↑ 35.7% |
| អង្ករបាក់៣០-៣៥% | Kg | 2,800 | • | • | • |
| ត្រីផ្ទក់(រស់) | Kg | 10,347 | → -2.4% | ↓ -13.7% | → -3.9% |
| ត្រីប្រា(រស់) | Kg | 6,800 | ↓ -5.9% | ↓ -8.8% | → -0.5% |
| ត្រីអណ្តែង(រស់) | Kg | 7,867 | → 4.2% | → -3.6% | → 2.9% |
| ត្រីងៀត(ផ្ទក់) | Kg | 26,702 | → -1.3% | → -2.5% | → 1.6% |
| ប្រហុក | Kg | 9,264 | → -2.5% | → 3.4% | → 3.2% |
| ត្រីពោធិ៍ | Kg | 10,333 | • | • | • |
| ត្រីខ្យា | Kg | | • | • | • |
| ត្រីសណ្តាយ | Kg | | • | • | • |
| សាច់ជ្រូកពាជាន់ | Kg | 13,954 | ↓ -6.1% | ↓ -9.8% | ↓ -14.9% |
| ឆ្អឹងជំនីជ្រូក | Kg | 12,667 | • | • | • |
| ឆ្អឹងជ្រូកស៊ុប | Kg | 10,000 | • | • | • |
| ជើងជ្រូក | Kg | 10,000 | • | • | • |
| សាច់គោឃារ | Kg | 15,524 | ↓ -5.3% | ↓ -8.5% | ↓ -20.5% |
| សាច់មាន់ (បីសាសន៍) | Kg | 14,295 | ↑ 7.2% | → -1.9% | → 0.7% |
| សាច់មាន់ (ស៊ីភី) | Kg | 10,000 | • | • | • |
| ស៊ុតទា | 10 eggs | 5,025 | ↓ -7.3% | ↓ -13.0% | ↓ -6.4% |
| ស៊ុតទាប្រៃ | 10 eggs | 6,972 | → -1.0% | → -3.8% | → 0.4% |
| ប្រេងឆា | 5 litres | 24,717 | → -4.9% | ↓ -7.3% | ↓ -17.1% |
| អំបិលម៉ត់អ៊ីយូត | Kg | 1,273 | → 2.5% | → 0.5% | → -4.6% |
| ទឹកត្រី (របបង្គងប៉ាក) | 730 ml | 3,425 | → -1.1% | → -0.2% | → 1.3% |
| សណ្តែកដី* | Kg | 9,774 | → -3.9% | → -1.6% | → -1.8% |
| សណ្តែកសៀង | Kg | 5,568 | ↑ 7.4% | → 0.3% | → 3.5% |
| សណ្តែកខៀវ | Kg | 5,933 | → -0.8% | → -0.7% | → 0.3% |
| ត្រកួន | Kg | 2,808 | ↓ -14.6% | ↓ -14.0% | ↓ -12.0% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ ឆ្នាំមុន |
|---|---|---|---|---|---|
| ការ៉ុត* | Kg | 3,063 | → -1.8% | → -3.0% | ↓ -12.4% |
| ស្ពៃក្តោបបាស* | Kg | 4,655 | → -4.0% | ↓ -6.3% | ↓ -6.8% |
| ស្លឹកម្រុំ* | Kg | 5,850 | ↑ 14.5% | ↑ 12.4% | ↑ 15.2% |
| ស្ពៃក្រញាញ់* | Kg | 3,148 | ↓ -12.0% | ↓ -34.1% | ↓ -10.1% |
| ស្ពៃតឿ* | Kg | 3,248 | ↓ -7.8% | ↓ -26.9% | → -4.6% |
| ស្ពៃចង្កឹះ | Kg | 2,953 | ↓ -8.0% | ↓ -28.9% | → -0.2% |
| ស្ពៃខៀវ* | Kg | 3,079 | ↓ -13.4% | ↓ -22.8% | → -3.1% |
| ផ្ទីដូង* | Kg | 3,504 | ↓ -17.1% | ↓ -16.7% | ↓ -18.1% |
| ស្លឹកងប់* | Kg | 5,544 | → 0.7% | → 2.4% | ↑ 5.2% |
| ត្រយូយល្ពៅ* | Kg | 5,081 | → -2.6% | ↑ 11.3% | ↑ 5.9% |
| ផ្លែល្ពៅ* | Kg | 2,443 | → -3.2% | → 1.6% | ↓ -15.2% |
| ឃ្លោក* | Kg | 2,675 | ↓ -7.4% | → 2.3% | • |
| ត្រឡាច | Kg | 2,870 | ↑ 16.2% | ↑ 14.8% | ↑ 25.7% |
| ត្រប់វែង | Kg | 2,985 | → -3.3% | → -0.2% | ↓ -21.0% |
| ត្រប់ស្រួយ* | Kg | 3,309 | ↓ -5.9% | ↑ 6.3% | ↓ -10.8% |
| ប៉េងប៉ោះ* | Kg | 3,443 | ↓ -30.6% | ↓ -15.3% | ↓ -20.3% |
| ននោងមូល | Kg | 2,514 | ↓ -12.7% | ↓ -10.0% | ↓ -16.6% |
| ននោងជ្រុង* | Kg | 2,685 | ↓ -8.2% | ↓ -5.6% | ↓ -11.1% |
| ល្ហុងខ្ចី* | Kg | 1,281 | → 0.8% | → -4.2% | ↓ -24.7% |
| សណ្តែកកួរ | Kg | 4,638 | → 3.7% | ↑ 20.8% | ↑ 21.9% |
| ត្រយូងចេក* | Kg | 2,377 | → 4.9% | → -1.8% | ↑ 5.4% |
| ផ្កាខាត់ណា* | Kg | 4,841 | ↓ -31.4% | ↓ -39.1% | ↓ -14.3% |
| ដើមខាត់ណា* | Kg | 4,056 | ↓ -28.4% | ↓ -33.0% | ↓ -11.2% |
| ដំឡូងផ្កាពណ៌លឿង* | Kg | 2,230 | ↓ -13.3% | ↓ -13.0% | ↓ -29.3% |
| ខ្ទឹមសរ | Kg | 7,073 | → -1.1% | → -0.7% | ↑ 37.3% |
| អំពិលទុំ (មានគ្រាប់) | Kg | 3,756 | ↓ -5.2% | → -3.1% | ↓ -8.7% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង ១ ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ ឆ្នាំមុន |
|---|---|---|---|---|---|
| អំពិលទុំ (អត់គ្រាប់) | Kg | 8,000 | • | • | • |
| ព្រលឹត | Kg | 3,333 | • | • | • |
| ត្រួយស្អំ | Kg | 16,333 | • | • | • |
| ត្រួយននោង | Kg | 3,187 | • | • | • |
| ត្រួយ ឬ ផ្កាអង្គារដី | Kg | 7,667 | • | • | • |
| ផ្សិតអំបោះ | Kg | 8,000 | • | • | • |
| ស្ពៃក្តោប | Kg | 2,500 | • | • | • |
| ស្ពៃបូកគោ | Kg | 3,333 | • | • | • |
| សណ្តែកបណ្តុះ | Kg | 2,667 | • | • | • |
| ក្តឹបឱឡឹក | Kg | 2,208 | • | • | • |
| ពោតបារាំង | Kg | 5,333 | • | • | • |
| ស្ពៀតពោត | Kg | 2,333 | • | • | • |
| ផ្លែពោត | Kg | 3,333 | • | • | • |
| ផ្លែត្នោតខ្ចី(ចិតរួច) | Kgl | 5,000 | • | • | • |
| ត្រសក់ | Kg | 2,000 | • | • | • |
| ម្ទេសត្រាវ | Kg | 4,500 | • | • | • |
| ម្ទេសផែថាវ | Kg | 2,458 | • | • | • |
| ទំពាំង | Kg | 8,167 | • | • | • |
| ចេកណាំវ៉ាទុំ | Kg | 2,102 | → -2.8% | ↓ -7.2% | → -2.5% |
| ស្វាយកែវរមៀតទុំ | Kg | 2,500 | → 0.0% | ↑ 75.4% | ↓ -21.1% |
| ម្នាស់ទុំ | Kg | 2,912 | • | • | • |
| ទឹកដោះគោស្រស់ | 140 ml | 1,980 | → -3.5% | ↓ -6.9% | ↑ 20.2% |
| កូកាកូឡា | 330 ml | 1,997 | → -0.1% | → -0.1% | → 0.5% |
| សាំងធម្មតា | litre | 4,111 | → -2.4% | ↓ -8.6% | → -2.9% |
| ម៉ាស៊ូត | litre | 4,093 | → -1.9% | ↓ -10.8% | ↓ -9.6% |
| ជីអ៊ុយរ៉េ | Kg | 2,764 | → -4.5% | ↓ -6.6% | ↓ -21.0% |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- • គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤
ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)
iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឱ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.8 | 34,701 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 10.3 | 28,650 |
| Meat | Pork | 3.1. សាច់ជ្រូកពងជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 14.3 | 17,686 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 8.0 | 2,897 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 5.6 | 2,167 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.0 | 21,007 |
| Tuber | Sweet Potato | 8.25. ដំឡូងជ្វាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.5 | 1,462 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **108,600** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឱ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*
*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៩ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*
*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*
*[4] បច្ចុប្បន្នភាពទីផ្សារ និងការតាមដានតាមរដូវកាល ខែមករា ឆ្នាំ២០២៤ WFP ប្រចាំប្រទេសកម្ពុជា។*